សលាកប័ត្រព័ត៌មានប្រចាំខែ
MONTHLY NEWSLETTER
លេខៈ ៤០ ខែមករា ឆ្នាំ២០០៩

# ឃ្លាំមើល សាលាក្តីខ្មែរក្រហម
KHMER ROUGE TRIBUNAL (KRT) WATCH

គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ_សមាគមការពារសិទ្ធិមនុស្សកម្ពុជា
CAMBODIAN HUMAN RIGHTS ACTION COMMITTEE
ADHOC - CARAM - CCPCR - CDP - CHHRA - CKIMHRDA - CSD - CWCC - GENEROUS - HROTP - IDA - KKKHRO - KKKHRDA - KID - KIND - KSA - KYA - LAC - PDP -PJJ - VIGILANCE

## អង្គជំនុំជម្រះសាលាដំបូងនឹងបើកសវនាការបឋម លើករណីអតីតប្រធានគុកទួលស្លែង ឌុច

យោងទៅតាមសេចក្តីប្រកាសព័តិមានរបស់អង្គជំនុំជម្រះសាលាដំបូង នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា "សាលាដំបូង" ការបើកសវនាការបឋមដើម្បីជំនុំជម្រះទៅលើអតីតមេគុកទួលស្លែង ឬមន្ទីរស.២១ ឈ្មោះ កាំង ហ្កេកអ៊ាវ ហៅ ឌុច នឹងប្រព្រឹត្តទៅនៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ ខាងមុខនេះ។ អង្គចៅក្រមចម្រុះសាសន៍ប្រាំរូប ដែលនឹងចូលរួមនៅក្នុងពេលបើកសវនាការបឋមជាលើកដំបូងទៅលើសំណុំរឿងអតីតមេដឹកនាំ និងអ្នកទទួលខុសត្រូវជាន់ខ្ពស់ខ្មែរក្រហមនេះរួមមាន លោក និន ណុល (ប្រធានសាលាដំបូង) លោកស្រី ស៊ីលវៀ ខាតរ៉ាយ (Silvia Cartwright ជនជាតិញូហ្សេលែន) លោក យ៉ា សុខន លោក ហ្សង់ម៉ាក ឡាវែញ (Jean Marc Lavergne- ជនជាតិបារាំង) និងលោក ធូ មណី។

បើយោងទៅលើការចោទប្រកាន់របស់សហព្រះរាជអាជ្ញា លោកស្រី ជា លាង និងលោក រ៉ូប៊ឺត ពើទិត ជនត្រូវចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច នេះ ត្រូវបានជាប់ចោទពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម (ជាបទល្មើសកម្រិតអន្តរជាតិ) អំពើមនុស្សឃាត និងអំពើទារុណកម្ម (បទឧក្រិដ្ឋកម្រិតជាតិ)។ សំណុំរឿងរបស់ជនត្រូវចោទរូបនេះ ត្រូវបានបញ្ចប់ការស៊ើបអង្កេតរួចរាល់ ដោយសហចៅក្រមស៊ើបអង្កេត ហើយបន្ទាប់មកសហចៅក្រមស៊ើបអង្កេតបានបញ្ជូនសំណុំរឿងនេះ ដើម្បីដាក់ជូនអង្គចៅក្រមសាលាដំបូង បើកសវនាការបឋម នៅថ្ងៃទី១៧ ខែកុម្ភៈ ខាងមុខនេះ។ ប៉ុន្តែ ប្រសិនណាតុលាការមិនទាន់កាត់សេចក្តី នោះគេនៅមិនទាន់ដឹងថា ឌុច នឹងត្រូវមានទោស ឬយ៉ាងណានោះនៅឡើយទេ ព្រោះនេះ ជាគោលការណ៍ច្បាប់ ដែលចែងថា *"ការសន្មត់ថាគ្មានទោស ដរាបណាតុលាការមិនទាន់សំរេចថាមានទោស"*។



*អតីតមេគុកទួលស្លែង ឈ្មោះ កាំង ហ្កេកអ៊ាវ ហៅ ឌុច*

បច្ចុប្បន្នអតីតប្រធានមន្ទីរស.២១ ដែលត្រូវគេចោទប្រកាន់ថាត្រូវទទួលខុសត្រូវចំពោះការសម្លាប់ និងការធ្វើទារុណកម្មយ៉ាងសាហាវយង់ឃ្នង ឈ្មោះ កាំង ហ្កេកអ៊ាវ រូបនេះ ត្រូវបានដាក់ឃុំខ្លួនបណ្តោះអាសន្ននៅក្នុងមន្ទីរឃុំខ្លួនបណ្តោះអាសន្ន ក្រោយពីត្រូវបានចាប់ខ្លួនមុនគេ (ក្នុងចំណោមអ្នកផ្សេងទៀត) កាលពីខែកក្កដា ឆ្នាំ២០០៧ ដោយបានផ្ទេរពីមន្ទីរឃុំខ្លួននៃតុលាការយោធា។ ដើម្បីធានាបាននូវយុត្តិធម៌ និងជាគោលការណ៍ច្បាប់ ជនត្រូវចោទ ឌុច មានមេធាវីពីររូបកំពុងការពារក្តីឱ្យ គឺ លោកមេធាវី ការ សាវុត្ថ និង លោកមេធាវី ហ្វ្រង់ស្វ័រ រូហ្ស (François Roux- ជនជាតិបារាំង)។

នៅក្នុងឱកាសខិតជិតមកដល់ នៃសវនាការជាលើកដំបូង ដែលប្រជាពលរដ្ឋខ្មែរបាននឹងកំពុងទន្ទឹងរង់ចាំយូរមកនោះ អង្គចៅក្រមនៃសាលាដំបូង ក៏បានចេញសេចក្តីណែនាំស្តីពីកាលបរិច្ឆេទចុងក្រោយសំរាប់ជនរងគ្រោះ ដែលបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងដែលបានស្នើសុំវិធានការការពារផ្សេងៗពីអង្គជំនុំជម្រះ ពាក់ព័ន្ធសំណុំរឿងប្រឆាំងជនត្រូវចោទ ឈ្មោះ ឌុច ឱ្យពន្លឿនការដាក់ពាក្យសុំទៅកាន់ការិយាល័យនៃអង្គភាពជនរងគ្រោះ មកត្រឹមថ្ងៃទី០២ ខែកុម្ភៈ ខាងមុខ ដើម្បីធានាថា សវនាការប្រព្រឹត្តទៅបានប្រកបដោយភាពត្រឹមត្រូវ និងឆាប់រហ័សទៅតាមនីតិវិធីជាធរមាន ដោយមានការ គោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនជាប់ចោទ និងមានការការពារឱ្យបានត្រឹមត្រូវចំពោះជនរងគ្រោះ និងសាក្សីផងដែរ។ ជាក់ស្តែង កិច្ចប្រជុំពិភាក្សាស្តីពីការកំណត់ការបរិច្ឆេទ និងដំណើរការប្រព្រឹត្តទៅរបស់សាលាដំបូង ត្រូវបានរៀបចំឡើងកាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៩ កន្លងទៅនេះ ដោយមានការចូលរួមរបស់ចៅក្រម និងភាគីពាក់ព័ន្ធដូចជា អង្គភាពជនរងគ្រោះ ផ្នែកការពារសាក្សី និងអ្នកជំនាញ ព្រមទាំងផ្នែកការពារជនជាប់ចោទផងដែរ។

# សិក្ខាសាលាបង្ហាញលទ្ធផលស្ដីពី អត្តចរិតរបស់ប្រជាពលរដ្ឋកម្ពុជាអំពីសាលាក្ដីខ្មែរក្រហម

កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០០៩កន្លងទៅ គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា បានរៀបចំឱ្យមានសិក្ខាសាលាបង្ហាញលទ្ធផល នៃការស្ទាបស្ទង់មតិ ស្ដីពី អត្តចរិតរបស់ប្រជាពលរដ្ឋកម្ពុជា ទាក់ទិនការកសាងសង្គមឡើងវិញ និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬហៅកាត់ថាជា *"សាលាក្ដីខ្មែរក្រហម"* ដែលត្រូវបង្ហាញដោយក្រុមអ្នកស្រាវជ្រាវ ឯករាជ្យ មកពីសាកលវិទ្យាល័យកាលីហ្វ័រនីញ៉ា នៃសហរដ្ឋអាមេរិក។

ថ្លែងនៅក្នុងឱកាសស្វាគមន៍ និងបើកសិក្ខាសាលានេះ លោក **វ៉ុលហ្វែង ម៉ូល័រ** (Wolfgang Moellers) តាំងនាមគណៈកម្មាធិការរៀបចំ និងជានាយកនៃអង្គការសេវាកម្មអភិវឌ្ឍន៍អាល្លឺម៉ង់ (ded) បានមានប្រសាសន៍ថា ការសិក្សាស្រាវជ្រាវអំពីអត្តចរិតរបស់ប្រជាពលរដ្ឋខ្មែរទាក់ទិន នឹងការយល់ឃើញអំពីការកសាងសង្គមជាតិឡើងវិញ ក្រោយពីរបបខ្មែរក្រហមបានបញ្ចប់ទៅ និងដំណើរប្រព្រឹត្ត ទៅរបស់សាលាក្ដីខ្មែរក្រហមដោយក្រុមអ្នកស្រាវជ្រាវឯករាជ្យ គឺមានសារៈសំខាន់សំរាប់ឱ្យមានការយកចិត្តទុកដាក់បន្ថែមទៀត និងបំពេញការចង់បាន និងការរំពឹងទុករបស់ប្រជាពលរដ្ឋកម្ពុជាអំពីបញ្ហាស្វែងរកយុត្តិធម៌ តាមរយៈការកាត់សេចក្ដីអតីតមេដឹកនាំខ្មែរក្រហម និងអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើង នៅក្នុងរបបប៉ុលពត ៣ឆ្នាំ ៨ខែ ២០ម្ភៃថ្ងៃកន្លងទៅ។




*រូបពីស្ដាំទៅឆ្វេង: លោក សុក សំអឿន លោក វ៉ុលហ្វែង ម៉ូល័រ និងលោក អេរីក ស្ដូវើរ*

ចំណែកឯលោក **អេរីក ស្ដូវើរ** **(Eric Stover)** ដែលជាប្រធានក្រុមអ្នកស្រាវជ្រាវស្ទាបស្ទង់មតិ មកពីសាកលវិទ្យាល័យកាលីហ្វ័រនីញ៉ានេះ បានមានប្រសាសន៍ថា លោកធ្លាប់បានធ្វើការស្រាវជ្រាវអត្តចរិត និងការយល់ដឹងរបស់ប្រជាពលរដ្ឋទៅលើឧក្រិដ្ឋកម្ម ធ្ងន់ធ្ងរនៅប្រទេសមួយចំនួនដែលមានលក្ខណៈស្រដៀងគ្នានឹងឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជាដែរ។ ដូចនេះ ការស្ទង់មតិនេះ បង្ហាញនូវលទ្ធផលសំខាន់ៗមួយចំនួនអំពី តំរូវការឱ្យមានការបង្កើនការយល់ដឹងនូវដំណើរប្រព្រឹត្តទៅនៃសាលាក្ដីខ្មែរក្រហមទៅដល់ប្រជាពលរដ្ឋ ពីព្រោះថា ភាពជោគជ័យរបស់សាលាក្ដីនេះពិតប្រាកដ ក៏អាស្រ័យលើការចូលរួម និងយល់ដឹងរបស់ប្រជាពលរដ្ឋដែរ។

ខាងក្រោមនេះ ជាលទ្ធផលសង្ខេបដែលបានរកឃើញនៅក្នុងការស្ទាបស្ទង់មតិនេះ ដែលបានធ្វើឡើងចាប់ពីថ្ងៃទី៩ ខែកញ្ញា រហូត ដល់ថ្ងៃទី១ ខែតុលា ឆ្នាំ២០០៨:

- **ការយល់ដឹងអំពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា:** ៣៩%នៃអ្នកផ្ដល់ចម្លើយក្នុងការស្ទង់មតិរបស់យើង មិនមានការយល់ដឹងអំពីអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជាឡើយ ហើយជិត ពាក់កណ្ដាលនៃអ្នកផ្ដល់ចម្លើយ (៤៦%) មានការយល់ដឹងនៅមានកម្រិត។ នៅក្នុងចំណោមអ្នកដែលមានកម្រិតយល់ដឹងខ្លះអំពីអង្គជំនុំ ជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ៥៣% បានរៀបរាប់យ៉ាងគ្រប់គ្រាន់ អំពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះថា ជាតុលាការកូនកាត់ ដែលមានចៅក្រម និងបុគ្គលិកជាជនជាតិខ្មែរ និងអន្តរជាតិ។ ទោះជាយ៉ាង ណាក៏ដោយ ៨២% នៃ អ្នកផ្ដល់ចម្លើយមិនអាចប្រាប់ឈ្មោះ

មេដឹកនាំទាំងប្រាំនាក់ ដែលសព្វថ្ងៃរងការចោទប្រកាន់ និងរង់ចាំកាត់ទោសទេ។ នៅក្នុងចំណោមអ្នកដែលបានឮអំពីអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា ប្រភពព័ត៌មានសំខាន់ដែលពួកគេបានទទួលមានវិទ្យុ (៨០%) និងទូរទស្សន៍ (៤៤%)។ ២៨% នៃអ្នកផ្តល់ចម្លើយទាំងនេះ បានរាយការណ៍ថា បានមើលកម្មវិធីជាក់លាក់ផ្សាយតាមទូរទស្សន៍អំពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយញឹកញាប់ជាង គេគឺជាប្រភេទព័ត៌មាន (៤៥%) និងរឿងខ្លីៗ (១៦%)។ ភាគច្រើនបំផុត នៃអ្នកផ្តល់ចម្លើយ (៩៨%) បានប្រាប់ថា ពួកគេនឹងមើលការកាត់ក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បើសិនជាគេផ្សាយផ្ទាល់តាមទូរទស្សន៍។

- **ការយល់ដឹង និងការរំពឹងទុកអំពីអង្គជំនុំជម្រះវិសាមញ្ញក្នុង តុលាការកម្ពុជា:** ជាទូទៅអ្នកផ្តល់ចម្លើយដែលបានដឹងពី អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានផ្តល់តម្លៃខ្ពស់ចំពោះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះ។ ៨៧%នៃអ្នកផ្តល់ចម្លើយបានប្រាប់ថា តុលាការនឹងឆ្លើយតបចំពោះឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តដោយពួកខ្មែរក្រហម។ ប្រហែលពីរភាគបី (៦៧%) បានជឿថា ចៅក្រមអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងយុត្តិធម៌ និងអព្យាក្រឹត។ ៦៨%នៃអ្នកផ្តល់ចម្លើយបានជឿថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នឹងមានឥទ្ធិពលវិជ្ជមានមកលើជនរងគ្រោះដោយខ្មែរក្រហម និងគ្រួសាររបស់គេ។ ទោះជាយ៉ាងណាក៏ដោយ ក៏មានភាពយល់មិនច្បាស់លាស់នៅក្នុងចំណោមអ្នកផ្តល់ចម្លើយខ្លះអំពីសត្យានុម័ត និងសុចរិតភាពនៃតុលាការដែរ។ មួយភាគបីនៃអ្នកផ្តល់ចម្លើយបានប្រាប់ថា តុលាការមិនអព្យាក្រឹតហើយ ២៣%មានអារម្មណ៍ថា តុលាការនេះពុករលួយ។ អ្នកផ្តល់ចម្លើយមានការសង្ឃឹមទុកយ៉ាងខ្លាំងចំពោះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ នៅក្នុងចំណោមអ្នកដែលមាន *"ការយល់ដឹងតិចតួច"* ពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ២៦% បាននិយាយថាតុលាការនឹងនាំមកនូវយុត្តិធម៌ ហើយ២០% បានប្រាប់ថា តុលាការនឹងដាក់ទណ្ឌកម្មដល់អ្នកមានទោស។ ទោះជាយ៉ាងណាក៏ដោយ ៣៧%មិនបានដឹងថា តើអង្គជំនុំជម្រះវិសាមញ្ញកំពុងនឹងបំពេញការងារអ្វីផង។

- **អនុសាសន៍ចំពោះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា:** អ្នកផ្តល់ចម្លើយដែលមានការយល់ដឹងយ៉ាងហោចណាស់បានខ្លះៗអំពីតុលាការនេះមានឱកាសធ្វើអនុសាសន៍មួយ ចំពោះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ សមស្របនឹងការយល់ដឹងនិងការរំពឹងទុករបស់ពួកគេ អ្នកផ្តល់ចម្លើយប្រាថ្នាចង់ឱ្យតុលាការកាត់ក្តីឱ្យបានឆាប់រហ័ស (៣០%) ហើយឱ្យតុលាការនេះ យុត្តិធម៌ និងឯករាជ្យ (២២%)។ ១៧% បានប្រាប់ថា ពួកគេមិនដឹងថា តើត្រូវធ្វើអនុសាសន៍យ៉ាងដូចម្តេចផង។

- **បញ្ហាសំណង:** ចៅក្រមនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានអំណាចគ្រប់គ្រងសំណងជា សមូហភាព ជានិមិត្តរូប និងផ្លូវចិត្ត តែមិនមែនជាប្រាក់កាសទេ សម្រាប់ផ្តល់ឱ្យក្រុមខ្លះនៃជនរងគ្រោះ (ដូចជា ដើមបណ្តឹងរដ្ឋប្បវេណី ជាដើម)។ សំណងបែបនេះអាចមានជាការកសាងរូបចម្លាក់ សង់ស្តូបអនុស្សាវរីយ៍ ដាក់ឈ្មោះថ្មីឱ្យទីកន្លែងសាធារណៈ រៀបចំទិវារំឮកលុបបំបាត់កំណត់ត្រាអំពីឧក្រិដ្ឋកម្ម ចេញសេចក្តីប្រកាសអំពីមរណភាព គាស់យកឆ្អឹងសាកសពពីក្នុងដី និងរៀបចំកប់ឆ្អឹងខ្មោចសាជាថ្មី។ ភាគច្រើនបំផុតនៃអ្នកផ្តល់ចម្លើយ (៨៨%) បាននិយាយថា សំណង គួរផ្តល់ជូនជនរងគ្រោះដោយខ្មែរក្រហម ហើយសំណងនេះគួរផ្តល់ឱ្យសហគមន៍ទាំងមូល (៦៨%)។ លើសពីពាក់ កណ្តាលនៃអ្នកផ្តល់ចម្លើយ (៥៣%) បាននិយាយថា សំណងគួរជាប្រភេទណាដែលមានឥទ្ធិពលដល់ជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋកម្ពុជា រួមមាន សេវាសង្គម (២០%) ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ (១៥%) កម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ច (១២%) ផ្ទះសម្បែងនិងដីធ្លី (៥%) និងការផ្តល់សត្វចិញ្ចឹម អាហារ និងឧបករណ៍កសិកម្ម (១%)។

ដើម្បីឱ្យមានការកែលំអ និងបង្កើនការយល់ដឹងរបស់ប្រជាពលរដ្ឋខ្មែរអំពីដំណើរការរបស់សាលាក្តីនេះ ក្រុមអ្នកស្រាវជ្រាវបានស្នើនូវអនុសាសន៍សំខាន់ៗមួយចំនួនដូចខាងក្រោមនេះ:

- **ដោះស្រាយជាបន្ទាន់ និងប្រកបដោយប្រសិទ្ធភាព ចំពោះការនិយាយថាមានអំពើពុករលួយ និងកង្វះតម្លាភាពនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា:** ក្នុងចំណោមប្រជាពលរដ្ឋកម្ពុជា ដែលអាចយល់ដឹងពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានការគាំទ្រយ៉ាងខ្លាំងដល់កិច្ចការនេះ។ អ្នកផ្តល់ចម្លើយនៅក្នុងការស្ទង់មតិ នេះបានបង្ហាញនូវក្តីរំពឹងយ៉ាងខ្ពស់ថា តុលាការនឹងយុត្តិធម៌ និងឯករាជ្យ។ នេះ គឺជាដំណឹងល្អសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ប៉ុន្តែវាអាចអន្តរាយដោយងាយបើសិនជាការ

ចោទប្រកាន់អំពីអំពើពុករលួយនៅមានបន្ត។ អ្នកផ្តល់ចម្លើយ បានបង្ហាញនូវទំនុកចិត្តតិចតួចចំពោះប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ក៏ដោយសារមានអំពើពុករលួយ និងកង្វះជំនឿលើមន្ត្រីតុលាការ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មិនគួរឱ្យមានរឿងដដែលនេះកើតឡើងទៀតទេ។ ម្យ៉ាងវិញទៀត តុលាការគួរធានាថា ការកាត់ក្តីមានតម្លាភាព ហើយអនុវត្តឱ្យបានទាន់ពេលវេលា។

- **ផ្សព្វផ្សាយឱ្យបានទូលាយ និងបង្កើនកិច្ចប្រឹងប្រែងផ្សព្វផ្សាយរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា:** ការយល់ដឹងថ្នាក់ជាតិអំពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅត្រង់ចំណុចនេះ គួរឱ្យបានកម្រិតខ្ពស់ និងទាន់ពេល ដោយហេតុថា វាបានចាប់ដំណើរការនៅក្នុងឆ្នាំ២០០៦។តិចជាង១%នៃអ្នកដែលបានរស់នៅក្រោមរបបខ្មែរក្រហម (ចំនួនបួននាក់) បានចូលរួមនៅក្នុងសកម្មភាពផ្សព្វផ្សាយទាក់ទិននឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងរយៈពេល១២ខែមុនពេលធ្វើការស្ទង់មតិ។ ការជូនដំណឹងពីសេវាសាធារណៈអំពីតុលាការនេះ គួរផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍។ បទសម្ភាសន៍ជាមួយចៅក្រម និងបុគ្គលិក តុលាការ គួរធ្វើជាលក្ខណៈធម្មតាក្នុងអំឡុងពេលកាត់ក្តី ដើម្បីជួយនៅក្នុងការពន្យល់ទស្សនាទានផ្នែកច្បាប់ និងវិនិច្ឆ័យជូនសាធារណជន។ លើសពីនេះទៅទៀត សេចក្តីសង្ខេបប្រចាំសប្តាហ៍អំពីដំណើរការកាត់ក្តី គួរធ្វើជាកម្មវិធី បែបសន្ទនា ដែលជំរុញឱ្យ មានកិច្ចពិភាក្សា ហើយដែលគួរតែចាក់ផ្សាយ តាមវិទ្យុ និងទូរទស្សន៍។

- **ចាត់តាំងបុគ្គលិកមួយរូបឱ្យបម្រើការជា "មន្ត្រីទំនាក់ទំនងផ្នែកអប់រំ" សម្រាប់ម្ចាស់អំណោយ អង្គការមិនមែនរដ្ឋាភិបាល និងរាជរដ្ឋាភិបាលកម្ពុជា:** កាតព្វកិច្ចបឋមរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក៏ដូចជា តុលាការទាំងអស់ផ្សេងទៀត គឺការកាត់ក្តីដោយយុត្តិធម៌ និងជាសាធារណៈ។ បានសេចក្តីថា តុលាការស្ថិតនៅក្នុងគោលជំហរតែមួយនៅក្នុងការបំពេញការងារ និងជាកាតាលីករ សម្រាប់កម្មវិធីអប់រំទាំងឡាយដែលនឹងផ្សារភ្ជាប់សកម្មភាពរបស់តុលាការទៅនឹងប្រវត្តិសាស្ត្រកម្ពុជា។ ប្រព័ន្ធសិក្សានៃប្រទេសកម្ពុជា មិនបានសំរេចដល់គោលដៅនៅក្នុងការអប់រំយុវជនអំពីឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមឡើយ។ ការធ្វើការជាមួយគ្នារវាងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ម្ចាស់អំណោយ អង្គការមិនមែនរដ្ឋាភិបាល និងក្រសួងអប់រំគួរប្រើឱកាសដែលមិនទាន់មានពីមុននៅក្នុងការបង្កើតកម្មវិធីសិក្សា ដែលមានដាក់បញ្ចូលនូវអត្ថបទប្រវត្តិសាស្ត្រ និងឯកសារសម្រាប់មើល ដែលបានមកពីការកាត់ក្តីនៅពេលខាងមុខ សម្រាប់ប្រើប្រាស់នៅសាលាបឋមសិក្សា និងមធ្យមសិក្សា។ ឯកសារសម្រាប់អប់រំទាំងនេះ ក៏អាចប្រើជាផ្នែកមួយនៃកេរ្តិ៍តំណែលរបស់តុលាការដែរ។

- **ទទួលស្គាល់ថា ប្រជាពលរដ្ឋកម្ពុជាភាគច្រើន ដែលយល់ឃើញខ្លួនឯងថាជាជនរងគ្រោះដោយខ្មែរក្រហម និងប្រាថ្នាចង់បានទម្រង់ខ្លះនៃសំណងជាសមូហភាព និងជានិមិត្តរូប:** បញ្ហាបន្ទាន់មួយសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវបានបង្ហាញនៅក្នុងគំហើញ ដែលភាគច្រើននៃអ្នកផ្តល់ចម្លើយបានប្រាប់ថា វាមានសារៈសំខាន់ច្រើនសម្រាប់ប្រទេសឱ្យផ្តោតការយកចិត្តទុកដាក់មកលើបញ្ហានានាដែលប្រជាពលរដ្ឋកម្ពុជាកំពុងប្រឈមនៅក្នុងជីវភាពប្រចាំថ្ងៃរបស់ខ្លួនជាជាងមកលើឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តដោយពួកខ្មែរក្រហម។ ការនេះកាន់តែជំរុញដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវតែស្វែងរកវិធីធ្វើសកម្មភាពនានាចំពោះកង្វល់បច្ចុប្បន្ន និងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋកម្ពុជា។ ការផ្តល់នូវសំណងបែបណាមួយ ជាពិសេសសំណងដែលផ្តោតលើការផ្តល់សេវាសង្គម និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ប្រហែលជាអាចជួយដោះស្រាយសេចក្តីត្រូវការនេះបានមួយចំណែកផងដែរ។

**ព័ត៌មានសំខាន់:**

ប្រសិនបើ លោកអ្នកចាប់អារម្មណ៍ចង់ចូលរួមដាក់ពាក្យបណ្តឹង**ជាភាគីដើមបណ្តឹងរដ្ឋប្បវេណី** និង**ជាសាក្សីនៅចំពោះមុខសាលាក្តីខ្មែរក្រហម**

សូមទាក់ទង: សមាគមអាដហុក, វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ និងមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម ដែលមាននៅតាមខេត្ត/ក្រុង។

*ទស្សនៈទាំងឡាយដែលមាននៅក្នុងអត្ថបទនៃសលាកប័ត្រព័ត៌មាននេះ មិនមែនឆ្លុះបញ្ចាំងពីទស្សនៈរបស់ អ៊ិន.អ៊ី.ឌី(NED) និង ឌី.អ៊ី.ឌី(DED) ទេ។*

**ឧបត្ថម្ភមូលនិធិដោយ: អ៊ិន.អ៊ី.ឌី និង ឌី.អ៊ី.ឌី**

NED The National Endowment for Democracy *Supporting freedom around the world*

ded Deutscher Entwicklungsdienst

*លោកអ្នកអាចស្រាវជ្រាវបន្ថែមនៅលើទំព័រ Website ខាងក្រោម*




ស្តាប់កម្មវិធីផ្សាយតាមវិទ្យុរៀងរាល់ថ្ងៃពុធ ម៉ោង ៥:៣០ - ៦:៣០ ល្ងាច FM ១០២